ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តស្វាយរៀង
សំណុំរឿងរដ្ឋប្បវេណី
លេខ:១២៤ ចុះថ្ងៃទី២១
ខែកក្កដា ឆ្នាំ២០២១
**សាលក្រមរដ្ឋប្បវេណី**
លេខ:**១១៧**(ក)ចុះថ្ងៃទី
១៥ ខែធ្នូ ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តស្វាយរៀង

-កាលបរិច្ឆេទបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២
-កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ។

## សាលក្រមរដ្ឋប្បវេណី

-ចៅក្រមជំនុំជំរះ [redacted] ចៅក្រមសាលាដំបូងខេត្តស្វាយរៀង ។
-ក្រឡាបញ្ជីសវនាការ [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តស្វាយរៀង ។

## សំណុំរឿងរដ្ឋប្បវេណី រវាង:

-ដើមចោទឈ្មោះ [redacted] វណ្ណថន ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរជាងសំណង់ មានទីលំនៅសព្វថ្ងៃនៅ [redacted] ។ មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទលោក [redacted] ។

-ចុងចម្លើយឈ្មោះ [redacted] **សារិន** ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅ [redacted] ។ មេធាវីតំណាងដោយអាណត្តិ(គ្មាន)។

## អង្គហេតុ និងចំណុចវិវាទ

**១-ការទាមទាររបស់ដើមចោទ**: ប្តឹងសុំតុលាការចេញសាលក្រមសម្រេច:

ក-សុំបញ្ជាក់ពីនត្តិភាពរវាងអាពាហ៍ពិពាហ៍ខ្លួននិងឈ្មោះ [redacted] សារិន ។

**ខ-សុំបែកចែកទ្រព្យសម្បត្តិរួមមាន:**

១-ដីភូមិទំហំប្រហែល១៥មx៣០ម និងផ្ទះសង់អំពីឈើប្រក់ដំបូលស៊ីប្រូស៊ីម៉ង់ត៍ ទំហំប្រហែល៦មx៨ម ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

២-ដីភូមិទំហំប្រហែល៣០មx១០០ម ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

៣-ដីភូមិទំហំប្រហែល៦០មx១០០ម ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

៤-ដីភូមិទំហំប្រហែល៣០មx១០០ម ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

Scanned with CamScanner

៥-ដីភូមិទំហំប្រហែល ២០អា ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

៦-ដីភូមិទំហំប្រហែល ៣អា ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

៧-ដីភូមិទំហំប្រហែល ៨អា ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

៨-ម៉ូតូម៉ាកហុងដាសេ១២៥ សេរីឆ្នាំ២០១៤ ចំនួន១គ្រឿង ។

៩-គោចំនួន២ក្បាល។

១០-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

ពាក្យបណ្តឹងតបរបស់ចុងចម្លើយចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០២១ ។

## អង្គហេតុដែលជាមូលហេតុ

-តាមពាក្យបណ្តឹងចុះថ្ងៃទី១៦ខែកក្កដាឆ្នាំ២០២១របស់ឈ្មោះ [redacted] វណ្ណថន (ដើមចោទ) បានអះអាងបញ្ជាក់ថាៈខ្លួនប្តឹងសុំឲ្យតុលាការចេញសាលក្រមសម្រេចសេចក្តីៈសុំបញ្ជាក់ពីនត្តិភាពវាងអាពាហ៍ពិពាហ៍ខ្លួននិងប្រពន្ធឈ្មោះ [redacted] សារិន **សុំបែកចែកទ្រព្យសម្បត្តិរួមមានៈ** ដីភូមិទំហំប្រហែល១៥មx៣០ម និងផ្ទះសង់អំពីឈើប្រក់ដំបូលស៊ីប្រូស៊ីម៉ង់ត៍ ទំហំប្រហែល៦មx៨ម ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ,ដីភូមិទំហំប្រ ហែល៣០ម x១០០ម ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង, ដីភូមិទំ ហំប្រហែល៦០មx១០០ម ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ,ដីភូមិទំហំប្រហែល៣០មx១០០ម ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយ រៀង , ដីភូមិទំហំប្រហែល ២០អា ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយ រៀង , ដីភូមិទំហំប្រហែល ៣អា ស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង , ដីភូមិទំហំប្រហែល៨អាស្ថិតនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង , ម៉ូតូម៉ាក ហុងដាសេ១២៥ សេរីឆ្នាំ២០១៤ ចំនួន១គ្រឿង,គោចំនួន២ក្បាល, ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ដោយសំអាងហេតុថាៈកាលពីអំឡុងឆ្នាំ១៩៨៧ ខ្លួនបានរៀបការជាមួយចុងចម្លើយឈ្មោះ [redacted] សារិន តែពុំបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ទេ រស់នៅជាមួយគ្នាបង្កើតបានកូនចំនួន៣នាក់គឺ កូនទី១ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស កើតនៅឆ្នាំ១៩៨៧ កូនទី២ឈ្មោះ [redacted] វិសាល ភេទប្រុស កើតនៅឆ្នាំ១៩៩៣ និងកូនទី៣ឈ្មោះ [redacted] ភក្រា ភេទស្រី កើតនៅឆ្នាំ១៩៩៦(សព្វថ្ងៃជានីតិជន)។ ការរស់នៅជាមួយគ្នាមិនចុះសម្រុងជាមួយគ្នា ដោយសារចុងចម្លើយពេលខ្លួនមានជម្ងឺចុងចម្លើយមិនជួយមើលថៃ និងមិនផ្គត់ផ្គង់ម្ហូបអាហារ ដែលជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាពុំអាចរស់នៅជា

មួយគ្នាបានទេ ។ ដោយឡែកចំពោះទ្រព្យសម្បត្តិរួមមាន ដីភូមិ និងដីស្រែចំនួន៧កន្លែង ខ្លួនសុំចែកម្នាក់៣ក់កណ្តាល ។

**២-ការអះអាងរបស់គូភាគី**:

ក/ការអះអាងរបស់ដើមចោទឈ្មោះ [redacted] **វណ្ណថន** បានធ្វើសេចក្តីថ្លែងការណ៍ទាំងនៅក្នុងនីតិវិធីត្រៀមលើកទី១និងលើកទី២ ក៏ដូចក្នុងនីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ថា: ខ្លួនប្តឹងសុំឲ្យតុលាការចេញសាលក្រមសម្រេច: សុំបញ្ជាក់ពីនត្ថិភាពអាពាហ៍ពិពាហ៍ រវាងខ្លួននិងចុងចម្លើយឈ្មោះ [redacted] សារិន ដោយសំអាងលើហេតុថា: កាលពីអំឡុងឆ្នាំ១៩៨៧ ខ្លួនបានរៀបការតាមទំនៀមទម្លាប់ប្រពៃណីជាមួយចុងចម្លើយ ឈ្មោះ [redacted] សារិន រៀបការរួចប្តីប្រពន្ធខ្លួនពុំបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវនៅសាលាឃុំទេ ដោយគ្រាន់តែរស់នៅជាមួយគ្នាជាធម្មតា ។ រស់នៅជាមួយគ្នាប្តីប្រពន្ធខ្លួនបង្កើតបានកូនចំនួន៣នាក់គឺកូនទី១ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស កើតនៅឆ្នាំ១៩៨៧ កូនទី២ឈ្មោះ [redacted] វិសាល ភេទប្រុស កើតនៅឆ្នាំ១៩៩៣ និងកូនទី៣ឈ្មោះ [redacted] កត្រា ភេទស្រី កើតនៅឆ្នាំ១៩៩៦ (សព្វថ្ងៃកូនជានីតិជន) ។ រស់នៅជាមួយគ្នាខ្លួននិងចុងចម្លើយរស់នៅមិនចុះសម្រុងជាមួយគ្នា ក្នុងពេលខ្លួនធ្លាក់ខ្លួនឈឺប្រពន្ធមិនគិតគូដល់ខ្លួននិងជាងនេះទៅទៀតខ្លួននិងចុងចម្លើយរស់នៅបែកគ្នាជាង១ឆ្នាំហើយ ដែលជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាពុំអាចរស់នៅជាមួយគ្នាជាប្តីប្រពន្ធវិញបានទេ ។ ចំពោះទ្រព្យសម្បត្តិរួមប្តីប្រពន្ធខ្លួនគឺមានដីភូមិ និងដីស្រែចំនួន៧កន្លែង គឺខ្លួនចែកគ្នាម្នាក់៣ក់កណ្តាល ។

ខ-ការអះអាងរបស់ចុងចម្លើយឈ្មោះ [redacted] **សារិន** បានធ្វើសេចក្តីថ្លែងការណ៍តបទាំងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ និងលើកទី២ តែនៅក្នុងនីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់បញ្ជាក់ថា: ខ្លួនពិតជាបានរៀបការតាមទំនៀមទំលាប់ប្រពៃណី ជាមួយដើមចោទឈ្មោះ [redacted] វណ្ណថន កាលពីក្នុងអំឡុងឆ្នាំ១៩៨៧ រៀបការរួចប្តីប្រពន្ធខ្លួនពុំបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅសាលាឃុំទេ ដោយគ្រាន់តែរស់នៅជាមួយគ្នាជាធម្មតា ។ រស់នៅជាមួយគ្នាប្តីប្រពន្ធខ្លួនបង្កើតបានកូនចំនួន៣នាក់គឺកូនទី១ ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស កើតនៅឆ្នាំ១៩៨៧ កូនទី២ឈ្មោះ [redacted] វិសាល ភេទប្រុស កើតនៅឆ្នាំ១៩៩៣ និងកូនទី៣ឈ្មោះ [redacted] កត្រា កើតនៅឆ្នាំ១៩៩៦( សព្វថ្ងៃកូនជានីតិជន)។ រស់នៅជាមួយគ្នាកន្លងមកខ្លួននិងដើមចោទរស់នៅមិនចុះសម្រុងជាមួយគ្នា មូលហេតុដោយសារដើមចោទមានស្រីនៅក្រៅផ្ទះ ដើមចោទបានយកប្រាក់ទៅរកស៊ីបានខាតបង់អស់ពីខ្លួន ចំពោះរឿងដើមចោទប្តឹងសុំលែងខ្លួនព្រមលែងដែរ ។ ដោយឡែកទ្រព្យសម្បត្តិរួមខ្លួនពុំព្រមបែងចែកឱ្យទៅដើមចោទទេ មូលហេតុដោយដើមចោទចុះចោលផ្ទះដោយខ្លួនឯង គឺទុកទ្រព្យចែកឱ្យទៅកូន ។

Scanned with CamScanner

លោកមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] វណ្ណថន បានធ្វើសេចក្ដីសន្និដ្ឋានថាៈ សិទ្ធិលែងលះគ្នានៅក្នុងពេលនេះលោកមេធាវីទុកឱ្យកូនក្ដីលោកជាអ្នកសម្រេច តែដោយឡែកចំពោះទ្រព្យសម្បត្តិរួម មានជាដីភូមិ និងដីស្រែ លោកមេធាវីស្នើសុំឱ្យលោកចៅក្រមជំនុំជំរះសម្រេចបែងចែកមកឱ្យកូនក្ដីខ្លួនចំនួនពាក់កណ្ដាល ដោយទ្រព្យសម្បត្តិរួមទាំងអស់នោះគឺនៅក្នុងប្លង់នីមួយៗមានឈ្មោះ កូនក្ដីខ្លួន [redacted] វណ្ណថន(ដើមចោទ) និងឈ្មោះ [redacted] សារិន(ចុងចម្លើយ) ។

## ចំណុចវិវាទ:

-ដើមចោទ និងចុងចម្លើយ បានឯកភាពគ្នាលើការលែងលះ ។ តែភាគីដើមចោទ និងចុងចម្លើយ មិនឯកភាពគ្នាលើការបែងចែកទ្រព្យរួម ។

## អំពីភស្តុតាង

**-ដើមចោទ**:

-សៀវភៅគ្រួសារ (ថតចម្លង) ចំនួន ១ច្បាប់ ។

-វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ(ច្បាប់ថតចម្លង)ចំនួន៦ច្បាប់ ។

**-ចុងចម្លើយ**:

-ពាក្យបណ្ដឹងតបចុះថ្ងៃទី២០ខែកញ្ញា ឆ្នាំ២០២១(ច្បាប់ដើម)ចំនួន១ច្បាប់ ។

## សំអាងហេតុ

-ដើមចោទ និងចុងចម្លើយ ពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្ដីប្រពន្ធកាលពីអំឡុងឆ្នាំ១៩៨៧ ហើយដើមចោទ និង ចុងចម្លើយ ពុំបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅសាលាឃុំ ដោយគ្រាន់តែរស់នៅជាមួយគ្នាជាធម្មតា ។ ដើមចោទ និងចុងចម្លើយ បានព្រមព្រៀងគ្នាក្នុងការលែងលះគ្នា ។ គប្បីតុលាការពិនិត្យ និងសម្រេច ផ្អែកតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

-ក្នុងនីតិវិធីត្រៀមលើកទី១និងលើកទី២ក៏ដូចក្នុងពេលទាញហេតុផលដោយផ្ទាល់មាត់គឺៈ ភាគីដើមចោទ បានសុំឲ្យសម្រេចអំពីការលែងលះរវាងដើមចោទ និងឈ្មោះ [redacted] សារិន (ចុងចម្លើយ) ដោយមូលហេតុថាៈ ខ្លួនអស់មនោសញ្ចេតនាមិនអាចរស់នៅជាមួយគ្នាជាប្ដី.ប្រពន្ធតទៅទៀត ហើយមូលហេតុដោយដើមចោទ និងចុងចម្លើយរស់នៅមិនចុះសំរុងជាមួយគ្នា និងជាងនេះទៅទៀតខ្លួននិងចុងចម្លើយរស់នៅបែកគ្នាជាងជាង១ឆ្នាំហើយ ជាហេតុធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាពុំអាចរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធវិញបាន ហើយដែលចុងចម្លើយក៏បានយល់ព្រមក្នុងការលែងលះជាមួយដើមចោទផងដែរនោះ ។ គប្បីតុលាការលើកយកមកពិនិត្យពិចារណានិងសម្រេចទៅ តាមការព្រមព្រៀងរបស់គូភាគី ។

Scanned with CamScanner

-ដើមចោទឈ្មោះ [redacted] វណ្ណថន និងចុងចម្លើយឈ្មោះ [redacted] សារិន មានកូនចំនួន៣នាក់ តែកូនៗរបស់ដើមចោទនិងចុងចម្លើយ ពួកគេជានីតិជន ពេញវ័យជាពលរដ្ឋអស់ហើយ ។ ដែលចំណុចនេះ តុលាការពុំលើកយកមកពិនិត្យនិងពិចារណាទេ ។

-ទ្រព្យសម្បត្តិរួមរបស់ដើមចោទ និងចុងចម្លើយរួមមានៈវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:20051404-0019,លេខ:20051404-0090,លេខ:20051404-0172,លេខ:20051404-0173,លេខ:20051404-0138,លេខ:20051404-0187, ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ គឺចុងចម្លើយឈ្មោះ [redacted] សារិន សុំយកគ្រប់គ្រងទាំងអស់ និងថាពុំព្រមបែងចែកឱ្យទៅដើមចោទទេ ដោយហេតុថា ដើមចោទជាអ្នកចុះចេញពីផ្ទះដោយខ្លួនឯង ហើយទ្រព្យនេះចុងចម្លើយទុកបែងចែកឱ្យទៅកូនៗរបស់ខ្លួនទាំង៣នាក់ ។ តែដើមចោទឈ្មោះ [redacted] វណ្ណថន សុំទាមទារបែកចែកម្នាក់ពាក់កណ្តាល ។ ការមិនបានព្រមព្រៀងគ្នាលើការបែងចែកទ្រព្យសម្បត្តិរួមនេះ គប្បីតុលាការលើកយកមកពិនិត្យ ពិចារណា និងសម្រេចទៅតាមសភាពជាក់ស្តែង ផ្អែកតាមច្បាប់ ។

-តាមនីតិវិធីត្រៀមនិងទាញហេតុផលដោយផ្ទាល់មាត់បញ្ជាក់ថា:ដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: 20051404-0090 និង លេខ: 20051404-0138 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ គឺជាទ្រព្យផ្ទាល់ខ្លួនរបស់ដើមចោទ រីឯដីដែលមានក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: 20051404-0019 និង លេខ: 20051404-0172 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ជាទ្រព្យផ្ទាល់ខ្លួនរបស់ចុងចម្លើយឈ្មោះ [redacted] សារិន ។ដែលគប្បីតុលាការសម្រេចតាមការបញ្ជាក់របស់គូភាគី ។

-ចំពោះដីចំនួន២កន្លែងទៀត ដែលមានក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: 20051404-0173 និងលេខ:20051404-0187 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ គឺដីជាទ្រព្យរួមរបស់ដើមចោទ និង ចុងចម្លើយ ។ គប្បីតុលាការលើកយកមកពិចារណាសម្រេចតាមច្បាប់ ។

-ចំពោះគោចំនួន២ក្បាល និងម៉ូតូចំនួន១គ្រឿង ចុងចម្លើយឈ្មោះ [redacted] សារិន ថា ជារបស់កូនទេ ហើយដែលដើមចោទក៏ពុំមានភស្តុតាងថ្មីថា គោចំនួន២ក្បាល និងម៉ូតូចំនួន១គ្រឿង(មាននៅឡើយដែរ) ដែលចំណុចនេះតុលាការ មិនលើកយកមកពិនិត្យសម្រេចទេ ។

-បណ្តឹងតបចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ របស់ចុងចម្លើយឈ្មោះ [redacted] សារិន គប្បីតុលាការលើកមកពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់ ។

-ដើមចោទឈ្មោះ [redacted] វណ្ណថន និងចុងចម្លើយឈ្មោះ [redacted] សារិន ថាពួកខ្លួនទាំងពីរនាក់ពិតជាអស់មនោសញ្ចេតនាជាមួយគ្នាយ៉ាងពិតប្រាកដមែនហើយ។

-ផ្អែកតាមមាត្រា **៩៧៩-៩៨០** នៃក្រមរដ្ឋប្បវេណី ។

-បានឃើញមាត្រា ៦៤ នៃក្រមរដ្ឋប្បវេណី

## **<u>សេចក្តីសម្រេចបញ្ចប់</u>**

១-ឲ្យដើមចោទឈ្មោះ [redacted] **វណ្ណថន** ភេទប្រុស អាយុ៥៥ ឆ្នាំ ជាតិខ្មែរ និងចុងចម្លើយឈ្មោះ [redacted] **សារិន** ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ លែងលះគ្នាចាប់ពីពេលនេះតទៅ។

**២-បែងចែកទ្រព្យសម្បត្តិរួម:**

ក-ប្រគល់ដីមានក្នុងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:20051404-00៩០ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩,ដីមានក្នុងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:20051404-0138 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ និងដីដែលមានក្នុងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:20051404-0173 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ឱ្យទៅឈ្មោះ [redacted] វណ្ណថន(ដើមចោទ) គ្រប់គ្រង ។

ខ-ប្រគល់ដីមានក្នុងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: 20051404-0019 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩,ដីមានក្នុងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:20051404-0172 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ និងដីដែលមានក្នុងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:20051404-0187 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ឱ្យទៅឈ្មោះ [redacted] សារិន(ចុងចម្លើយ) គ្រប់គ្រង ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទជាអ្នកបង់ ។

៤-សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចំពោះមុខឈ្មោះ [redacted] **វណ្ណថន** (ដើមចោទ) និងឈ្មោះ [redacted] **សារិន** (ចុងចម្លើយ)។

-បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខានិងត្រា** [redacted]

**<u>បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម</u>**

ថ្ងៃចន្ទ១១រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ស្វាយរៀង ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជំរះ**

[redacted]

Scanned with CamScanner